## កម្រិតនៃការចូលរួមសហគមន៍

ការកើនឡើងនៃផលប៉ះពាល់

| | គោលដៅនៃការចូលរួមរបស់សហគមន៍ | ការសន្យាចំពោះសហគមន៍ | ឧទាហរណ៍<br>សូមចំណាំថា ឧទាហរណ៍ណាមួយអាចស្ថិតនៅក្នុងកម្រិតខុសៗគ្នា អាស្រ័យលើរបៀបដែលវាត្រូវបានរចនាឡើង |
|---|---|---|---|
| 5<br>ប្រគល់សិទ្ធិឱ្យ ឬសហគមន៍ដឹកនាំ | ដើម្បីដាក់ការសម្រេចចិត្តក្នុងដៃរបស់សហគមន៍ និង/ឬដើម្បីគាំទ្រសកម្មភាពនៃដំណើរការដែលផ្តួចផ្តើមជំរុញ និង/ឬដឹកនាំដោយសហគមន៍ | យើងនឹងអនុវត្តនូវអ្វីដែលអ្នកសម្រេចចិត្ត ឬធ្វើតាមការដឹកនាំរបស់អ្នកជាទូទៅលើផ្លូវឆ្ពោះទៅមុខ យើងនឹងផ្តល់ការគាំទ្រដែលត្រូវការដើម្បីឃើញគំនិតរបស់អ្នកទទួលបានជោគជ័យ។ | · ក្រុមការងារដឹកនាំដោយសហគមន៍<br>· ការផ្តល់ថវិកា និងការគាំទ្រសម្រាប់ដំណើរការដែលដឹកនាំដោយសហគមន៍<br>· ការកសាងការឯកភាពគ្នា<br>· ការសម្រេចចិត្តដោយមានការចូលរួម |
| 4<br>សហការ | ដើម្បីធ្វើជាដៃគូជាមួយសហគមន៍ក្នុងទិដ្ឋភាពនីមួយៗនៃការសម្រេចចិត្ត រួមទាំងការអភិវឌ្ឍ ជម្រើសនានា និងការកំណត់ដំណោះស្រាយដែលពេញចិត្ត | យើងនឹងរំពឹងលើអ្នកសម្រាប់ដំបូន្មាន និងនវានុវត្តន៍នៅក្នុងការបង្កើតដំណោះស្រាយ និងរួមបញ្ចូលដំបូន្មាន និងអនុសាសន៍របស់អ្នកទៅក្នុងសេចក្តីសម្រេចក្នុងវិសាលភាពអតិបរមាដែលអាចធ្វើទៅបាន។ | · ដំណើរការដែលមានការសន្ទនា និងកិច្ចសហការជាប្រចាំ និងជាបន្តបន្ទាប់<br>· ក្រុមប្រឹក្សាយោបល់<br>· គំរូវិទ្យាសាស្ត្រពលរដ្ឋ*<br>· គំរូវិទ្យាសាស្ត្រសហគមន៍**<br>· ភាពជាដៃគូជាមួយអង្គការតាមសហគមន៍ |
| 3<br>ចូលរួម | ដើម្បីធ្វើការដោយផ្ទាល់ជាមួយសហគមន៍នៅគ្រប់ដំណាក់កាលនៃដំណើរការ ដើម្បីធានាថាកង្វល់ និងសេចក្តីប្រាថ្នារបស់ពួកគេត្រូវបានស្វែងយល់ និងពិចារណាយ៉ាងជាប់លាប់ | យើងនឹងធ្វើការជាមួយអ្នក ដើម្បីធានាថាកង្វល់ និងសេចក្តីប្រាថ្នារបស់អ្នកត្រូវបានឆ្លុះបញ្ចាំងនៅក្នុងជម្រើសដែលបានបង្កើតឡើង និងផ្តល់មតិកែលម្អអំពីរបៀបដែលការរួមចំណែកនោះជះឥទ្ធិពលដល់ការសម្រេចចិត្ត។ | · សកម្មភាពដែលប្រធានបទ ឬអាទិភាពលេចឡើងដោយផ្អែកលើអ្វីដែលសំខាន់សម្រាប់សហគមន៍<br>· កិច្ចប្រជុំតាមសហគមន៍<br>· កិច្ចសម្ភាសតាមសហគមន៍<br>· សិក្ខាសាលាអន្តរកម្ម<br>· ក្រុមប្រឹក្សាយោបល់<br>· អាហារពេលល្ងាចសហគមន៍ |
| 2<br>ពិគ្រោះយោបល់ | ដើម្បីទទួលបានមតិកែលម្អពីសហគមន៍លើការវិភាគ ជម្រើស និង/ឬដំណោះស្រាយ | យើងនឹងជូនដំណឹងដល់អ្នក ស្តាប់ និងទទួលស្គាល់កង្វល់ និងសេចក្តីប្រាថ្នា និងផ្តល់មតិកែលម្អអំពីរបៀបដែលមតិយោបល់របស់សហគមន៍ជះឥទ្ធិពលដល់ការសម្រេចចិត្ត។ | · សកម្មភាពដែលផ្តោតលើការប្រមូលមតិកែលម្អ<br>· មតិយោបល់សាធារណៈ:<br>· ក្រុមផ្តោត<br>· ការស្ទង់មតិ<br>· កិច្ចប្រជុំតាមសហគមន៍<br>· កិច្ចសម្ភាសតាមសហគមន៍<br>· បញ្ជូរព័ត៌មានចល័ត / បញ្ជូរស្តាប់មតិ |
| 1<br>ជូនដំណឹង | ដើម្បីផ្តល់ឱ្យសហគមន៍នូវព័ត៌មានប្រកបដោយតុល្យភាព និងគោលបំណង ដើម្បីជួយពួកគេក្នុងការយល់ដឹងអំពីបញ្ហា ជម្រើស ឱកាស និង/ឬដំណោះស្រាយ | យើងនឹងជម្រាបជូនអ្នកឱ្យបានជ្រាបជាដំណឹង។ | · សន្លឹកព័ត៌មាន<br>· គេហទំព័រ<br>· វគ្គបើកចំហសម្រាប់សាធារណជន<br>· បទបង្ហាញ<br>· វគ្គស្វែងយល់ពីទិន្នន័យ<br>· ស្លាកសញ្ញាសម្រាប់ការអប់រំ |

* វិទ្យាសាស្ត្រពលរដ្ឋ គឺជាកិច្ចខិតខំប្រឹងប្រែងសហការគ្នារវាងសមាជិកសហគមន៍ និងអ្នកវិទ្យាសាស្ត្រ ដើម្បីបង្កើនចំណេះដឹងវិទ្យាសាស្ត្រ។ វាពាក់ព័ន្ធនឹងការសហការលើការប្រមូល ការវិភាគ និងការបកស្រាយទិន្នន័យ ដើម្បីដោះស្រាយបញ្ហាជាក់ស្តែង។

**នវិទ្យាសហគមន៍ គឺជាវិធីសាស្ត្រស្រាវជ្រាវដែលស្វែងរកការយល់ដឹងពីតម្រូវការ បំណងប្រាថ្នា បញ្ហាប្រឈម ឬសក្តានុពលវប្បធម៌របស់សហគមន៍។ វាទាមទារការចូលរួមយ៉ាងសកម្មពីសមាជិកសហគមន៍ក្នុងគ្រប់ដំណាក់កាលនៃការសិក្សា រួមទាំងការរចនាសំណួរស្រាវជ្រាវ ការប្រមូលទិន្នន័យ ការវិភាគ និងការបកស្រាយ។

*** តារាងនេះដកស្រង់ចេញពីគំរូជាច្រើន រួមមាន IAP2 មជ្ឈមណ្ឌលយុទ្ធសាស្ត្រចលនា និង ស្តង់ដាការចូលរួមសហគមន៍រដ្ឋ Massachusetts សម្រាប់គោលការណ៍ណែនាំរៀបចំផែនការសុខភាពសហគមន៍" (2017)។